CITY OF LONG BEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ២ ខែកក្កដាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចនឹងទទួលបានថវិកាចំនួន ៤០,២៨ លានដុល្លារពីមូលនិធិ CARES Act

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - បន្ទាប់ពីការអនុម័តនៃថវិការបស់រដ្ឋកាលីហ្វ័រញ៉ានៅថ្ងៃទី ៣០ ខែមិថុនាឆ្នាំ ២០២០ ទីក្រុងឡុងប៊ិចនឹងទទួលបានថវិកាចំនួន ៤០.២៨០.៤៩៤ ដុល្លារពីមូលនិធិច្បាប់មេរោគកូរ៉ូណជំនួយសង្គ្រោះនិងស្ថេរភាពសេដ្ឋកិច្ច (CARES Act) ដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែងឆ្លើយតបរបស់ទីក្រុងចំពោះការរីករាលដាលនៃជម្ងឺរាតត្បាត COVID-19។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "អាទិភាពរបស់យើងគឺការដែលនៅតែបន្តការពារដល់សុខភាពសាធារណៈនិងផ្តល់ការគាំទ្រដល់ប្រជាជនរបស់យើង។ ថវិកានេះនឹងអនុញ្ញាតឱ្យយើងបន្តធ្វើការទាំងនេះហើយយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអភិបាលរដ្ឋ Newsom សម្រាប់ការគាំទ្ររបស់គាត់។"

ដោយចំនួនប្រជាជនស្ថិតនៅក្រោមកម្រិតទាបដើម្បីទទួលបាននូវការបែងចែកថវិកាដោយផ្ទាល់តាមរយៈច្បាប់ CARES Act ទីក្រុងឡុងប៊ិចនឹងទទួលបានថវិការដ្ឋនៅក្នុងឆ្នាំ ២០២១ នៃសារពើពន្ធរបស់រដ្ឋវិញដែលផ្តល់ថវិកាចំនួន ៤៥០ លានដុល្លារដល់ទីក្រុងរដ្ឋកាលីហ្វ័រញ៉ាផ្សេងៗដែលមានលក្ខណៈសម្បត្តិគ្រប់គាន់ដែលមិនបានទទួលថវិកាពីរដ្ឋាភិបាលសហព័ន្ធ។

មូលនិធិ CARES Act ត្រូវបានកម្រិតចំពោះការប្រើប្រាស់មួយចំនួនដោយរដ្ឋាភិបាលសហព័ន្ធនិងផ្អែកលើគោលការណ៍ណែនាំដែលមានបច្ចុប្បន្នអាចផ្តល់ថវិកាដល់ទីក្រុងដោយស្របច្បាប់ក្នុងការឆ្លើយតបទៅនឹងរោគរាតត្បាតរួមទាំងការផ្តល់ថវិកាគាំទ្រដល់កិច្ចខិតខំផ្នែកសុខភាពសាធារណៈការគាំទ្រសហគមន៍ប្រជាជននិងអាជីវកម្មនិងការគាំទ្រភាពស្ថេរភាពផ្នែកសេដ្ឋកិច្ច។

បុគ្គលិកក្រុងនឹងផ្តល់គម្រូងអនុសាសន៍ទៅក្រុមប្រឹក្សាក្រុងនៅថ្ងៃទី ១៤ ខែកក្កដាឆ្នាំ ២០២០ ដែលនឹងគូសបញ្ជាក់អំពីការប្រើប្រាស់សក្តានុពលនៃមូលនិធិដើម្បីជួយក្នុងការឆ្លើយតបនឹងជម្ងឺរាតត្បាត។ ផ្នែកនីមួយៗគឺរួមមាន៖

- ការទូទាត់សំណងចំណាយលើសុខភាពសាធារណៈនិងចំណាយទីក្រុងដូចជាប្រាក់ខែបុគ្គលិក ការធ្វើតេស្ត៍ការតាមដានការទំនាក់ទំនងនិងកិច្ចខិតខំឆ្លើយតបបន្ទាន់របស់ក្រុង។
- ការចំណាយនាពេលអនាគតនៃការឆ្លើយតបនឹងជម្ងឺរាតត្បាតរហូតដល់ខែធ្នូឆ្នាំ ២០២០ ដែលជាពេលវេលាកំណត់នៃការដែលអាចចំណាយថវិកាពីមូលនិធិ CARES Act បាន។
- ចំណាយដោយផ្ទាល់លើការគាំទ្រដល់ការថែទាំប្រជាជនងាយរងគ្រោះ។
- កង្កើតកម្មវិធីដើម្បីគាំទ្រដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយ COVID-19។
- បង្កើតកម្មវិធីដើម្បីគាំទ្រដល់អាជីវកម្មនិងអង្គការមិនរកប្រាក់ចំណេញដែលរងផលប៉ះពាល់ដោយ COVID-19។

ព័ត៌មានលំអិតបន្ថែមស្តីពីអនុសាសន៍របស់បុគ្គលិកក្រុងលើការផ្តល់ថវិកាដល់កម្មវិធីដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់និងលើចំណាយផ្សេងៗនឹងមានជូននៅថ្ងៃច័ន្ទទី ៦ ខែកក្កដាឆ្នាំ ២០២០។ ក្រុមប្រឹក្សាក្រុងនឹងពិនិត្យនូវអនុសាសន៍របស់បុគ្គលិកក្រុងលើការផ្តល់ថវិកាដល់កម្មវិធីដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់និងលើចំណាយផ្សេងៗនៅថ្ងៃទី ១៤ ខែកក្កដាឆ្នាំ ២០២០។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

###